សលាកប័ត្រព័ត៌មាន ៖ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ច្បាប់ស្តីពី ឧ.ក.អ)
ស្ថានភាពបច្ចុប្បន្ននៃច្បាប់ ៖ ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើនៅខែធ្នូ ឆ្នាំ១៩៩៤ ។ មានច្បាប់ពាក់ព័ន្ធ និងផែនការធ្វើវិសោធនកម្ម ដែលអាចប៉ះពាល់ដល់ច្បាប់ស្តីពី ឧ.ក.អ ប៉ុន្តែដំណើរការនៃច្បាប់ទាំងនោះមានការយឺតយ៉ាវ ។
ចំណាត់ថ្នាក់របស់ ម.ស.ម.ក ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានចាត់ចំណាត់ថ្នាក់នៃច្បាប់ស្តីពី ឧ.ក.អ ជាពណ៌លឿង ៖ គោលបំណងដំបូងនៃច្បាប់ គឺដើម្បីបង្កើតស្ថាប័នឯករាជ្យដែលអាចត្រួតពិនិត្យលើប្រព័ន្ធតុលាការ ជាជំហានដ៏រីជ្ជមានមួយ ប៉ុន្តែ ច្បាប់ក្នុងទម្រង់បច្ចុប្បន្នមានបទប្បញ្ញត្តផ្ទុយនឹងគោលបំណងដែលចែងខាងដើម ។ ច្បាប់នេះគួរតែត្រូវបានពិនិត្យឡើងវិញសាជាថ្មី និងធ្វើវិសោធនកម្មដើម្បីពង្រឹងឯករាជ្យភាព និងលទ្ធភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ឧ.ក.អ) ជាពិសេស ដើម្បីបំបាត់ចោលនូវឥទ្ធិពលរបស់អំណាចនីតិប្រតិបត្តិ។



សេចក្តីផ្តើម

ឧ.ក.អ មានគោលបំណងជាស្ថាប័នដ៏ឯករាជ្យពិនិត្យមើលប្រព័ន្ធយុត្តាធិការ ។ ស្ថាប័ននេះមានអំណាចតែងតាំង ដំឡើងឋានៈ ចាត់វិធានការវិន័យ និងបញ្ឈប់ការងាររបស់ចៅក្រម ។ សលាកប័ត្រព័ត៌មាននេះ បង្ហាញនូវទិដ្ឋភាពទូទៅនៃការព្រួយបារម្ភចម្បង។ និងអនុសាសន៍របស់ ម.ស.ម.ក ចំពោះច្បាប់ស្តីពី ឧ.ក.អ ។ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ។

ច្បាប់ស្តីពី ឧ.ក.អ

ច្បាប់ស្តីពី ឧ.ក.អ ត្រូវបានអនុម័តដោយយោងតាមមាត្រា១៣៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា (រដ្ឋធម្មនុញ្ញ) ។ ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើក្នុងឆ្នាំ ១៩៩៤ ប៉ុន្តែ ឧ.ក.អ មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ រហូតមកដល់ឆ្នាំ១៩៩៨ ។ គោលបំណងនៃច្បាប់នេះ គឺដើម្បីបង្កើត ឧ.ក.អ ដែលមានតួនាទី "*ធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យរបស់ចៅក្រម និងដើម្បីធានាការប្រព្រឹត្តទៅនៃសាលាដំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ឲ្យដំណើរការបានល្អប្រសើរ*" ។ (មាត្រា១) ។ ច្បាប់នេះបានបន្ទរនូវរដ្ឋធម្មនុញ្ញ ដែលបានចែងថា ឧ.ក.អ នឹងមានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាប្រធាន ហើយសមាជិកមានដូចជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចៅក្រម បីរូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម (មាត្រា២) ។ អណត្តិរបស់សមាជិកដែលត្រូវបានជ្រើសតាំងគឺ ប្រាំឆ្នាំ (មាត្រា៤) ។ សេចក្តីសម្រេចនៃឧត្តមក្រុមប្រឹក្សាត្រូវយកតាមមតិភាគច្រើននៃសមាជិកវត្តមាន (លើកលែងតែប្រធាន) តាមរយៈការបោះឆ្នោតជាសម្ងាត់ ។ ករណីដែលមានការជាប់គាំងប្រធានអង្គប្រជុំជាអ្នកសម្រេច (មាត្រា៩) ។ ឧ.ក.អ សម្រេច និងលើកសេចក្តីស្នើដាក់ថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរការផ្តាច់ពីមុខងារ និងការដាក់ឲ្យនៅទំនេរ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការហួតងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ (មាត្រា១១) ។ ច្បាប់នេះក៏បានចែងផងដែរថា ឧ.ក.អ ត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ និងក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីដាក់ទោសទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា (មាត្រា១២) ។

ការបែងចែកអំណាច

មាត្រា៥១ នៃរដ្ឋធម្មនុញ្ញចែងថា "អំណាចត្រូវបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្ត អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ" ។ ចំណុចនេះត្រូវបានបន្ទរក្នុងមាត្រា១ ក្នុងច្បាប់ស្តីពី ឧ.ក.អ ដូចដែលបានរៀបរាប់ខាងលើ ។ ដូច្នេះ ឧ.ក.អ គួរតែមិនស្ថិតក្រោមឥទ្ធិពលនៃអំណាចនីតិប្រតិបត្តិនោះទេ ។ ប៉ុន្តែ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសមាជិកនៃអង្គនីតិប្រតិបត្តិ ក៏មានតួនាទីក្នុង ឧ.ក.អ ផងដែរ អាចនាំឲ្យប៉ះពាល់ដល់គោលការណ៍បែងចែកអំណាច ។ ម្យ៉ាងវិញទៀត ចៅក្រមទាំងបីរូប ដែលមានតួនាទីក្នុង ឧ.ក.អ មិនត្រូវបានបោះឆ្នោតជ្រើសតាំង ដូចដែលបានចែងក្នុងច្បាប់ស្តីពី ឧ.ក.អ នោះទេ ។ មាត្រា២០ និង២១ ដែលចាត់ទុកជាបញ្ញត្តអន្តរកាល បានចែងថាការបោះឆ្នោតជ្រើសតាំងចៅក្រម នឹងមិនទាន់អាចអនុវត្តបាន រហូតទាល់តែច្បាប់ស្តីពី លក្ខន្តិក:របស់ចៅក្រម និងព្រះរាជអាជ្ញាចូលជាធរមានជាមុន ហើយដោយសារថាមកទល់ពេលនេះ ច្បាប់នេះមិនទាន់បានអនុម័តនៅឡើយ ដូច្នេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវស្នើសុំទៅព្រះមហាក្សត្រជាអ្នកតែងតាំងចៅក្រមទាំងនោះវិញ ។ ដូច្នេះ សមាជិកប្លែនាក់ នៃ ឧ.ក.អ គឺជាផ្នែកមួយនៃអង្គនីតិប្រតិបត្តិ ឬមិនដូច្នោះទេក៏ត្រូវបានជ្រើសរើសដោយអង្គនីតិប្រតិបត្តិ ធ្វើឲ្យអំណាចនីតិប្រតិបត្តិមានសំឡេងខ្លាំងក្នុងការគ្រប់គ្រងប្រព័ន្ធតុលាការ ។ អំណាចនីតិ

ប្រតិបត្តិ អាចមានអាទិភាពក្នុងការជះឥទ្ធិពល គឺតាមរយៈដំណើរការរដ្ឋបាល និងថវិកា ។ ច្បាប់ស្តីពី ឧ.ក.អ បានចែងថា ថវិការបស់ ឧ.ក.អ ត្រូវគ្រោងក្នុងថវិការបស់ក្រសួងយុត្តិធម៌ ដែលនេះគឺកាន់តែផ្តល់ឱកាសបន្ថែមទៀតក្នុងការរងឥទ្ធិពល ។

តម្លាភាព

ច្បាប់ស្តីពី ឧ.ក.អ បង្ហាញពីកង្វះតម្លាភាព ។ ច្បាប់នេះបានដាក់កំហិតជាកាតព្វកិច្ចដល់សមាជិករបស់ ឧ.ក.អ និងអ្នកចូលរួមត្រូវរក្សាការសម្ងាត់នៃការប្រជុំទាំងឡាយរបស់ ឧ.ក.អ ហើយរាល់ការសម្រេចចិត្តទាំងអស់នឹងត្រូវធ្វើឡើងដោយការបោះឆ្នោតជាសម្ងាត់ ។ មិនតែប៉ុណ្ណោះ ក៏គ្មានលក្ខខណ្ឌ ឬដំណើរការច្បាស់លាស់សម្រាប់ការតែងតាំង ការដំឡើងឋានៈ និងការផ្អាកការងាររបស់ចៅក្រមនោះទេ ធ្វើឲ្យដំណើរការនេះមានមន្ទិលសង្ស័យថាអាចនឹងរងឥទ្ធិពលផ្នែកនយោបាយ និងផ្នែកសេដ្ឋកិច្ច ។

សមត្ថភាព

ច្បាប់ចែងថាសមាជិកទាំងប្រាំ របស់ ឧ.ក.អ អាចមានតួនាទី ដោយផ្អែកលើមូលដ្ឋានការតែងតាំងជាសាធារណៈដទៃទៀតដែលពួកគេមាន ។ ចំណុចនេះត្រូវបានរិះគន់ លើមូលដ្ឋានមួយថាដោយសារតែគ្មានពេលវេលាគ្រប់គ្រាន់ ធ្វើឲ្យសមាជិកទាំងនោះមិនអាចអនុវត្តការងាររបស់ខ្លួនក្នុង ឧ.ក.អ បានយ៉ាងពេញទំហឹងនោះទេ ។ ជាលទ្ធផល ធ្វើឲ្យ ឧ.ក.អ ជួបប្រជុំមិនសូវញឹកញាប់ និងខ្វះលទ្ធភាពក្នុងការធ្វើការស៊ើបអង្កេតយ៉ាងមានប្រសិទ្ធភាព ។ បន្ថែមពីលើនេះ ចំណុចដែលចៅក្រមបម្រុងមានការពាក់ព័ន្ធជាមួយនឹង ឧ.ក.អ អាចនឹងបណ្តាលឲ្យមានជាទំនាស់ផលប្រយោជន៍ ។ ឧទាហរណ៍ ចៅក្រមដែលមានឋានៈទាប អាចមានចំណែករួមក្នុងការតែងតាំង ឬចាត់វិធានការវិន័យមកលើចៅក្រមឋានៈខ្ពស់ ជាដើម ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ភាពចម្រូងចម្រាស់ថ្មីៗក្នុងការបដិសេធរបស់ ឧ.ក.អ ដើម្បីបញ្ជាក់ពីការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គឺលោកចៅក្រម ខាស់ស្តើ អានសើមេត បានចង្អុលឲ្យឃើញនូវចំណុចខ្វះខាតនៃច្បាប់ស្តីពី ឧ.ក.អ ក្នុងការបង្កើតនូវស្តាប់ឯកភាពរដ្ឋដែលមានសមត្ថភាពត្រួតពិនិត្យលើប្រព័ន្ធតុលាការ ជាពិសេស មានការអះអាងថាមានឥទ្ធិពលពីអំណាចនីតិប្រតិបត្តិ កង្វះតម្លាភាពក្នុងដំណើរការសម្រេចចិត្ត និងស្ថានភាពដែល សហចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាជាតិទាំងពីររូប សុទ្ធតែពាក់ព័ន្ធក្នុងការសម្រេចចិត្តរបស់ ឧ.ក.អ ។ ក្នុង *"ផែនការសកម្មភាពដើម្បីអនុវត្តយុត្តិសាស្ត្រកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ"* ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០៥ បានកត់សម្គាល់ថា ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ និងច្បាប់ស្តីពីវិសោធនកម្ម ចំពោះច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម នឹងត្រូវអនុម័តដើម្បីពង្រឹងសមត្ថភាពរបស់ ឧ.ក.អ ក្នុងការស៊ើបអង្កេត បង្កើនតម្លាភាពក្នុងការតែងតាំង ដំឡើងឋានៈ និងចាត់វិធានការវិន័យ និងបង្កើនឯករាជ្យភាព ។ បន្ថែមទៅលើ ការអនុម័តច្បាប់ទាំងបីខាងលើ សេចក្តីព្រាងនៃច្បាប់ទាំងនោះ គួរតែត្រូវបានដាក់ឲ្យមានការជជែកពិភាក្សាពីសាធារណជន ម.ស.ម.ក សូមផ្តល់អនុសាសន៍ចំពោះការធ្វើវិសោធនកម្មលើ ច្បាប់ស្តីពីវិសោធនកម្ម ចំពោះច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ដូចខាងក្រោម ៖

- គួរតែធ្វើវិសោធនកម្មច្បាប់ដើម្បីមិនអនុញ្ញាតឲ្យសមាជិកមនុ ៗ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចមានតួនាទីក្នុងក្រុមប្រឹក្សានេះ ។ ក្រៅពីព្រះមហាក្សត្រ ឧ.ក.អ ទាំងមូល គួរតែបង្កើតឡើងដោយការបោះឆ្នោតជ្រើសតាំងនៃបុគ្គលដែលមានអាជីពផ្នែកច្បាប់ រួមទាំងចៅក្រមដែលចូលនិវត្តន៍ និងសាស្ត្រាចារ្យផ្នែកច្បាប់ ។ មុខងារនេះ គួរតែជាការងារពេញម៉ោង ហើយប្រាក់បំណាច់គួរតែស័ក្តិសមចំពោះការងារ ។
- គួរតែមានការធ្វើវិសោធនកម្មដើម្បីចែងថាគម្រោងថវិកាត្រូវមានឯករាជ្យដាច់ពីក្រសួងយុត្តិធម៌ ។
- ច្បាប់គួរតែចែងជាពិសេសថា សមាជិកទាំងអស់មិនត្រូវជាចៅក្រមក្នុងដំណែង ឬជាសមាជិកនៃគណបក្សនយោបាយណាក្នុងពេលដែលពួកគេមានតួនាទីក្នុងក្រុមប្រឹក្សានេះទេ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោកស្រី ចក់ សុភាព (+៨៥៥ (0) ១១ ៥៤ ៣២ ១៣ ឬអ៊ីម៉ែល៖ chaksopheap@cchrcambodia.org **ឬកញ្ញា សាណា ឃ្លោស (+៨៥៥ (0) ៨៩ ៦១ ៤៣ ៣៤ ឬអ៊ីម៉ែល៖** sana.ghouse@cchrcambodia.org **។**

មច្ឆាប់រដ្ឋធម្មនុញ្ញ និងតាមទៅស្របមនុស្ស និងសិទ្ធិការណ៍គោលនៃល្បងសាកកាលដំណាក់ឆ្លងអាចនោះច្បាប់ថាតើ តាមទៅយោងច្បាប់ថ្នាក់ចំណាត់ក ចាត់.ម.ស. អន្តរជាតិ និងទាំងអនុវត្តកំពុងដែលជាតិដែរឬអត់។ ច្បាប់ដែលត្រូវបានចាត់ចំណាត់ថ្នាក់ពណ៌បៃតងត្រូវបានទទួលស្គាល់នៅក្នុងគំនិតរបស់ មត្រូវដែលក ច្បាប់.ម.ស. ប្រែកែការធ្វើសាឡើងវិញ និងពិនិត្យតែគួរដែលចំនួនមួយបារម្ភព្រួយសេចក្តីមានពណ៌លឿងថ្នាក់ចំណាត់ចាត់បាននិងច្បាប់ដែលបានចាត់ចំណាត់ថ្នាក់ពណ៌ក្រហមគឺបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះរដ្ឋធម្មនុញ្ញ និងសិទ្ធិគោលការណ៍នៃល្បងសាកកាលដំណាក់កាត់ឆ្លងមិនឬ/និង អន្តរជាតិជាតិ និងទាំងអនុវត្តកំពុងដែលច្បាប់ឬ/តគួរ ដូច្នេះ និង មនុស្សែបដិសេធ ទុកជាមោយ: ឬព្រាងសាថាថ្មីតាមការសមស្រប។